# សិលាចារឹកភូមិកំពីងពួយ K.៩៥៧

## ១- ព័ត៌មានទូទៅ

សិលាចារឹកនេះ រកឃើញនៅក្នុងឆ្នាំ១៩៥៩ ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់មកបានយកទៅរក្សាទុកនៅសារមន្ទីរជាតិ ក្រុងបាងកក។ ទីតាំងរកឃើញនេះ មានឈ្មោះជាភាសាថៃថា บ้านพังพวย មានន័យជាខ្មែរថា ភូមិកំពីងពួយ។ នៅពេលរកឃើញគេពុំមានកស្តុតាងបុរាណវិទ្យាអ្វីសេសសល់បន្តិចសោះ នៅតំបន់ក្បែរនោះ[១]។

ផ្ទាំងថ្មចារឹក ជាថ្មភក់ពណ៌ក្រហម មានរាងជាសន្លឹកសីមាទ្រវែង មានកម្ពស់១៥២ ស.ម. បន្ទារ៤៥ស.ម. និងកម្រាស់១២.៥ស.ម.[២]។ អត្ថបទចារឹកចារជាភាសាខ្មែរ នៅលើផ្ទៃសង្ខាង ដែលផ្ទាំងកមានចំនួន២២បន្ទាត់ ផ្ទាំងខដាច់ដោចនៅសល់តែ១៣បន្ទាត់។ អត្ថបទនៅផ្ទាំងក ចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ៨៦៣ (ត្រូវនឹងគ.ស. ៩៤១)[៣] និយាយពីព្រះរាជសាសន៍របស់ព្រះមហាក្សត្រ ត្រាស់បញ្ជាឱ្យសង់គោលសិលាចារឹកនាព្រះបុណ្យគ្រូសារអាចារ្យបរមាចារ្យក្នុងស្រុកវនបូរ ដែលផ្សំគ្នានឹងប្រាសាទគម្តែងអញជគតលិង្គបូរ និងការរៀបចំរណ្តាប់បូជាមានអាហារ ស្រែ អ្នកបម្រើ និងគោក្របី។ ព្រះមហាក្សត្រចេញបម្រាមមិនឱ្យទារយកភូម្យាករបស់ប្រាសាទគម្តែងអញជគតលិង្គបូរឡើយ។ អ្នកណាដែលពុំធ្វើតាមព្រះរាជបញ្ជានឹងត្រូវគេចាប់ដាក់ទ្រុងយកទៅកាត់ទោស។ ចំណែកសេចក្តីដែលសេសសល់នៅផ្ទាំងខ ធូលីជើងកំស្តែងអញស្រីរាជេន្ទ្រវម្ម នាំព្រះរាជសាសន៍ព្រះមហាក្សត្រត្រាស់បញ្ជាឱ្យសង់បង្គោលព្រំដីនៅទីនោះ ហើយចែងពីតង្វាយនិងបម្រាមថាមិនឱ្យទារយកភូម្យាករដែរ និងសូមឱ្យបម្រើចំពោះព្រះបុណ្យអាចារ្យបរមាចារ្យ។

---

[១] សឺដេស, ១៩៦៤។

[២] https://db.sac.or.th/inscriptions/inscribe/detail/316

[៣] សឺដេស, ១៩៦៤៖ មួយឆ្នាំមុនចប់រាជ្យព្រះបាទស្រីជ័យវរ្ម័ទី៤។

អត្ថបទដោយៈ ហ៊ុន ឈុនគេង និង ប៉ោ សុខរីន

## *២- អត្ថបទដើមជាអក្សរខ្មែរទំនើប*

### *មុខ ក*

*៚ //សិទ្ធិ ឱ្យ ស្វស្តិ៙//*

*១- ៨៦៣គក្ក[៤]ធត្តីកេតិគ្រាវនអា(ទិ)ត្យវារនុធូលីជេងកំស្តេង*

*២- អញ្ញគ្រីពជេន្ទ្រវម្ម៌បង្គំថ្វ្លងនិវេទនវ្រះបុន្យគោត្រអា*

*៣- ចាយ៌្យបរមាចាយ៌្យតគិស្រុកិវនបុរលេងសំគណានុវ្រះកំ*

*៤- ម្រតេងអញ្ញជគតិលិង្គបុរមានិវ្រះគាសនតកំស្តេងអញ្ញពជកុ*

*៥- លមហាមន្ត្រីស្តេញអញ្ញចតុពចាយ៌្យបន្ទូលិវ្រះគាសនត*

*៦- អាចាយ៌្យបាលភាគវតប្រត្យយប្រេមោកិសងគោលិប្រគស្តុត*

*៧- គិស្រុកិវន[៥]បុរនាវ្រះបុន្យគោត្រអាចាយ៌្យបរមាចាយ៌្យផ្សំគ*

*៨- ណានុកម្រតេងអញ្ញជគតិលិង្គបុរ៙ចាំចំនាំបយ៌្យងមាសិ២*

*៩- អក្ស[[ត]][៦]ជេ២ម្វាយិឆ្នាំស្រេវ្រះអំរិតគិត្រវាងទៅបូវ៌ល្វះតគោល*

*១០- ប្រសបិរុទ្រាលយទៅទក្សិណល្វះរ្នំមិទៅបគ្និមល្វះត្រវាងស្វា*

*១១- យិយ៌្យាបិទៅឧត្តរល្វះធ្និង្វស្រេងើងទៅទក្សិណឧទ្យាន[៧]ល្វហិជ្រលុះ*

*១២- ហស្រេជី[៨]គ្រីបទអំរិទក្សិណស្តុកិកទម្វទៅឧត្តរល្វហិតគិផ្ទូ*

---

[៤] *លោក សឺដេស អានជា «គក្ក»។ លោក ចេណ្ណឹរ អានជា «គក»។ នៅលើសំណៅផ្តិតគឺ «គក្ក» តែជើង «្ក» មានគំនូសធូតពីលើ ទើបប្រហែលជាធ្វើឱ្យលោក ចេណ្ណឹរ អានដូចនេះ។ ទោះជាយ៉ាងណាស្នាមនោះ យើងមិនច្បាស់ថាគេគូសលុបចោលទេ ព្រោះបើមើលលើស្នាមនោះ អាចកើតឡើងដោយការកោសធូតដោយមិនចេតនា។ ម្យ៉ាងទៀតសំណេរ «គក្ក» លេចឡើងនៅក្នុងសិលាចារឹក K.៨៣១៖ ប.២, ប.១០, ប.១៤; K.៤៤៤៖ ប.៥; និង K.៧៤២៖ ប.១ ដែរ។*

[៥] *អក្សរ «ន» ចារជ្រៀតពីលើ ចន្លោះ «វ» និង «បុ»។ យើងសង្កេតឃើញមានគំនូសបញ្ឈរសងខាង «ន»។*

[៦] *ការបន្ថែមនេះជាសំណើលោក ចេណ្ណឹរ។*

[៧] *អក្សរ «ន» ចារជ្រៀតពីលើ ចន្លោះ «ទ្យា» និង «ល្វ»។ មានគំនូសបញ្ឈរសងខាង «ន» ដែរ។*

[៨] *លោក សឺដេស អានដូចនេះដែរ។ លោក ចេណ្ណឹរ អានជា «ជិ» ប៉ុន្តែតាមការផ្ទៀងលើសំណៅផ្តិតគឺ «ជី»។*

*អត្ថបទដោយៈ ហ៊ុន ឈុនតេង និង ប៉ោ សុខវីន*

១៣- ប្រសបិតបោគីរី[៩] ស្រេបគ្និមស្ត(កិ)កទម្ងជំនូនិមេកំយាតាញិង
១៤- និរុវភូមិមនិកល្បនាសិទ្ធិតវ្រះ៙ខ្ញុំវ្រះតៃគុភាក្ញតនុក្ញ
១៥- និ[១០] ចោរតៃកទ្វាងនុក្ញនិចោរតៃជម៌្មនុក្ញន្ន[១១]៙ថ្មរុក្របិ៙
១៦- រ៉ំជាបិសុតន្រ្ត[១២] តខ្ញោញរិមយខ្ញោញស្រូខ្ញោញបយ៌្យងតមុ
១៧- ខគាបិដ្ឋោលិ[១៣] រ៉ំអាចិតិទារិភូម្យាករស្វតន្រ្តតកំម្រតេង(អ)
១៨- ញ៉ជគតិ[១៤] លិង្គបុរ៙នៅរុវអ្នកិតអមយ៌្យាទបិរំថ្ងៃតេ(ាយ)
១៩- វ្រះគាសនប្រេគ្រាមវូទ្ធចាបិបញ្ជរនាំទៅឱយិត[ក]ំ[ស្តេង]
២០- អញ៉ៃរាជកុលនុស្តេញ៉អញ៉ចតុរាចាយ៌្យបង្គំថ្យ[[ូងនិវេទន]][១៦]
២១- បិនិណ្ណ៍យ៙

**មុខ ខ**

១- ...[[គ្រីរាជេន្រ្ទ]][១៧] វម៌្មនុ...
២- ...[បន្ទ]លិវ្រះគាសនតប្រ...
៣- ...ប្រត្យយប្រេសងគោ[លិ]...
៤- ...[វ្រះករុ]ណាប្រសាទតស្តេញ៉អ(ញ៉)[[ចតុរាចាយ៌្យ]][១៨]...

---

[៩] លោក សឺដេស និងលោក ចេណ្ណឺរ អានជា «តបោគិរិ»ប៉ុន្តែតាមការផ្ទៀងផ្ទាត់លើសំណៅផ្តិតគឺ«តបោគីរិ»។
[១០] លោក សឺដេស មិនអាន។
[១១] លោក សឺដេស អានដូចនេះដែរ។ ចេណ្ណឺរ អានជា «ក្ញន» ប៉ុន្តែតាមការផ្ទៀងផ្ទាត់លើសំណៅផ្តិតគឺ «ក្ញន្ន»។
[១២] ពាក្យត្រឹមត្រូវគឺ «ស្វតន្ត្រ»។
[១៣] លោក ចេណ្ណឺរ អានជា «ដ្ឋលិ» ប៉ុន្តែតាមការផ្ទៀងផ្ទាត់លើសំណៅផ្តិតគឺ «ដ្ឋោលិ»។
[១៤] លោក ចេណ្ណឺរ អានជា «ជ្គតិ»។ តែនៅសង្វាងអក្សរ «គ» មានគំនូសបញ្ឈរដូចពេលដែលចារជ្រៀតអក្សរ «ន» (ប.៧ និង ប.១១) ដែរទើបយើងទាញបានថាគេចារជ្រៀតអក្សរ «គ» ពីក្រោមចន្លោះ «ជ» និង «តិ»។
[១៥] ជួសតាមពាក្យដូចគ្នានៅបន្ទាត់ទី៤។
[១៦] ជួសតាមពាក្យដូចគ្នានៅបន្ទាត់ទី២។
[១៧] លោក ចេណ្ណឺរ ជួសតាមអត្ថបទ ក បន្ទាត់ទី២។
[១៨] លោក ចេណ្ណឺរ ជួសតាមអត្ថបទ ក បន្ទាត់ទី៥។

អត្ថបទដោយៈ ហ៊ុន ឈុនតេង និង ប៉ោ សុខរីន

៥- ...ន្តវ្រះបុន្យនៃអាចាយ៌្យបរមាចាយ៌្យ...

៦- ...[ស្រុ]កិវនបុរសំគណានុកម្រតេងអញ៌ជ[គតិ]

៧- [[លិង្គបុរ]][១៩]០ចាំចំនាំតន្មុលជេ២បយ៌្យងមាសិ២ផ្ទៃ

៨- ...(គ)[២០]ក្តិម្វាយិវត្តម្វាយិវត្តម្វាយិឆ្នាំវេ

៩- ...គមោកិបង្គំមរ្វំជាបិខ្ញោញ៌ិវិមយខ្ញោ

១០- [[ញ៌ិស្រូខ្ញោ]][២១]ញ៌ិបយ៌្យងមុខគាបិផ្ទោលិរ្វំជាបិទារិ

១១- [[ភូម្យាក]][២២]រហោងលេងបំរេតវ្រះបុន្យនៃអាចាយ៌្យ

១២- ...[២៣]វ្រះអវធីមនិស្តាបនាអាយិវ្រះសភាបិបោ

១៣- ...តោយវ្រះគាសន០//

## ៣- អត្ថបទប្រែសម្រួល

### មុខ ក

ឱម! សិទ្ធិ សួស្តី។

(១-៤) មហាសករាជឆ្នាំ៨៦៣ ទី៦កើត ខែស្រាពណ៍ ថ្ងៃអាទិត្យ។ នូវធូលីជើងកំស្តែងអញស្រីរាជេន្ទ្រវម៌្មក្រាបថ្វាយបង្គំទូល(ព្រះមហាក្សត្រ ពី)ព្រះបុណ្យគ្រូសារអាចារ្យបរមាចារ្យនៅស្រុកវនបូរដែល(ត្រូវ)ឡើងផ្សំគ្នាជាមួយនឹងព្រះគម្តែងអញជគតលិង្គបូរ។

(៤-៨) មានព្រះរាជសាសន៍ដល់កំស្តែងអញរាជកុលមហាមន្ត្រី (និង)ស្តែញអញចតុរាចារ្យឱ្យនាំព្រះរាជសាសន៍ដល់អាចារ្យបាលជាភាគវ័ត(និងជា)ប្រត្យ័យ ត្រាស់បញ្ជាឱ្យមកសង់គោលសិលាចារឹកនៅស្រុកវនបូរ នាព្រះបុណ្យគ្រូសារអាចារ្យបរមាចារ្យផ្សំគ្នាជាមួយនឹងគម្តែងអញជគតលិង្គបូរ។

---

[១៩] «កម្រតេងអញ៌ជគតិលិង្គបុរ» មាននៅអត្ថបទ ក បន្ទាត់ទី៣-៤ និងទី៨។

[២០] លោក ចេណ្ណឹរ មិនអាន។

[២១] លោក សឺដេស ជួសតាមអត្ថបទ ក បន្ទាត់ទី១៦។

[២២] លោក សឺដេស ជួសតាមអត្ថបទ ក បន្ទាត់ទី១៧។

[២៣] លោក ចេណ្ណឹរ ជួសដោយ «បរមាចាយ៌្យ» និងថែមដើម្បីឱ្យឃ្លាមានន័យគ្រប់គ្រាន់ថា «សងិគោលិ»។

អត្ថបទដោយៈ ហ៊ុន ឈុនតេង និង ប៉ៅ សុខវីន

(៨-៩) រៀបចំតង្វាយប្រេង២មាស ស្រូវ២ដើ (ក្នុង)មួយឆ្នាំ។

(៩-១១) ស្រែព្រះអំពីត្រពាំងទៅខាងកើតលុះដល់បង្គោលព្រំដីប្រសព្វនឹងវុទ្រាល័យ ទៅត្បូងលុះដល់ភ្នំ ទៅលិចលុះដល់ត្រពាំងស្វាយរៀប ទៅជើងលុះដល់ស្ទឹង។

(១១-១២) ស្រែរងេង/រងៀង ទៅត្បូងឧទ្យានលុះដល់ជ្រលុះ។

(១២-១៣) ស្រែជីស្រីបទ ចាប់ពីខាងត្បូងស្តុកខ្ពុល្ដទៅជើងលុះដល់ផ្លូវប្រសព្វនឹងតបោគិរី។

(១៣-១៤) ស្រែខាងលិចស្តុកខ្ពុល្ដជាតង្វាយមេកំយាយតាញធនដូចដីដែលបានថ្វាយសិទ្ធិកាន់កាប់ដល់ព្រះ។

(១៤-១៥) អ្នកបម្រើព្រះ៖ តៃសុភាក្រឹតនិងកូនចៅ, តៃកន្ទាងនិងកូនចៅ, តៃធម៌និងកូន។

(១៥) គោក្របី។

(១៦-១៨) (តង្វាយទាំងនេះ)ពុំគប្បីនៅក្រោមការគ្រប់គ្រងរបស់ខ្ញាញវិស័យ ខ្ញាញស្រូវ ខ្ញាញប្រេង និងមេឈ្មួល (និង)ពុំអាចទារយកកូម្យាករនៅក្រោមការគ្រប់គ្រងរបស់គម្តែងអញជគតលិង្គបូរ(ឡើយ)។

(១៨-២១) នូវអ្នកដែលអមារយាទ(/គ្មានសណ្ដាប់)ពុំធ្វើតាមព្រះរាជសាសន៍ (ព្រះមហាក្សត្រ)ត្រាស់បញ្ជាឱ្យចាស់ស្រុកចាប់ដាក់ទ្រុង នាំទៅឱ្យកំស្តែងអញរាជកុល(មហាមន្ត្រី) និងស្តេញអញ(ចតុរាចារ្យ) ក្រាបថ្វាយបង្គំទូល(ព្រះមហាក្សត្រ)ដើម្បីដាក់ទោស។

**មុខ ខ**

(១-៧) ...ស្រីរាជេន្ទ្រវម្ម័និង...នាំព្រះរាជសាសន៍ដល់... ប្រត្យ័យ ត្រាស់បញ្ជាឱ្យសង់បង្គោលព្រំដី... ព្រះរាជទានដល់ស្តេញអញចតុរាចារ្យ...ព្រះបុណ្យនៃអាចារ្យបរមាចារ្យ...ស្រុកវនបូរផ្សំគ្នាជាមួយនឹងគម្តែងអញជគតលិង្គបូរ។

(៧-៨) រៀបចំតង្វាយអង្ករ២ដើ ប្រេង២មាស ផ្លែ... (ស)ត្តិមួយវាត់ មួយវាត់ក្នុងមួយឆ្នាំ វេ...មកបង្គំ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង បៅ សុខវីន

(៩-១០) ពុំគប្បីខ្ញោញវិស័យ ខ្ញោញស្រូវ ខ្ញោញប្រេង មេឈ្មួលយកពន្ធ ពុំជាបីមកទារយកភូម្យាករឡើយ។

(១១-១៣) សូមឱ្យបម្រើចំពោះព្រះបុណ្យនៃអាចារ្យបរមាចារ្យ សង់គោលកំណត់ព្រំដីព្រះដែលបានស្ថាបនានៅឯព្រះសភា...តាមព្រះរាជសាសន៍។

## ៤- សន្និដ្ឋានរួម

សិលាចារឹក K.៩៥៧ មានតម្លៃខាងទិដ្ឋភាពនៃការកាន់កាប់ដីធ្លី តង្វាយ ពន្ធដារ និងទោសទណ្ឌកាលពីសម័យបុរាណ។ យើងឃើញពីព្រះរាជតួនាទីរបស់ព្រះមហាក្សត្រក្នុងរឿងនេះដែរ ដោយព្រះអង្គជាអ្នកចេញព្រះរាជបញ្ញាឱ្យមន្ត្រីទៅសង់គោលសិលាចារឹកនិងបង្គោលព្រំដី ចែងពីរណ្ដាប់បូជាសម្រាប់ថ្វាយទៅប្រាសាទ ហាមប្រាមមិនឱ្យយកពន្ធនិងទារយកភូម្យាកររបស់ប្រាសាទ ហើយជនដែលធ្វើខុសពីព្រះរាជបញ្ញានេះក៏ព្រះអង្គជាអ្នកដាក់ទោស។

## ៥- វាក្យសព្ទ

| | |
|---|---|
| កល្បនា | (សំ.) រៀបចំ គ្រឿងរណ្ដាប់ដែលគេរៀបចំ។ |
| កំស្តេង | ឋានន្តរនាមមន្ត្រីជាន់ខ្ពស់ មហាមន្ត្រី មហាសេនាបតី អ្នកអង្គម្ចាស់ និងមន្ត្រីសង្ឃជាន់ខ្ពស់[២៤]។ |
| ខ្ញោញបយ្យ៉េង | មេខាងប្រេង។ |
| ខ្ញោញវិមយ | មេតំបន់។ |
| ខ្ញោញស្រូ | មេខាងស្រូវ។ |
| គោត្រ | (សំ.) វង្ស ត្រកូល ពូជផៅ ក្រុមគ្រួសារ។ |
| គ្រាមវ្ទ្ធ | ចាស់ស្រុក ចាស់ភូមិ។ |
| ចំនាំ | (ន.) អ្វីដែលគេរៀបចំ គ្រឿងរណ្ដាប់។ |

[២៤] វង់ សុធារ៉ា, ២០១៦។

| | |
|---|---|
| ចាំ | (កិ.) រៀបចំ។ |
| ឆត្តី | ជាពាក្យប្រាក្រឹត ត្រូវនឹងពាក្យសំស្រ្កឹតថា «ឞប្តី» និងពាក្យបាឡី «ឆដ្ឋី» មានន័យថាទីប្រាំបី។ |
| ជេ | ខ្នាតវាស់ធញ្ញជាតិ, កញ្ជើ។ |
| តន្ទុល | (សំ.) អង្ករ។ |
| ថ្មុរ | គោ។ |
| ទារ | ទារយក ទទួល។ |
| និណ្ណ៌យ | (សំ.) កាត់ក្តី។ |
| និវេទន | (សំ.) ទូលថ្វាយ ជម្រាបដំណឹង។ |
| បង្គុំថ្បូង | ក្រាបថ្វាយបង្គំ គឺផ្គុំដៃប្រណម្យដាក់លើក្បាល។ |
| បញ្ជរ | (សំ.) ទ្រុង។ |
| បយ៉្យង | ប្រេង។ |
| ប្រត្យយ | (សំ.) មន្ត្រីជំនិតរបស់ព្រះរាជា។ |
| ភាគវត | (សំ.) ពាក្យនេះមានន័យពីរយ៉ាង។ ទី១ សំដៅដល់អ្វីដែលមានទំនាក់ទំនងឬចេញមកពីព្រះភគវ័ត គឺព្រះនារាយណ៍ឬព្រះក្រឹស្នា, ដែលជាទីសក្ការៈដាដើម។ ទី២ សំដៅដល់ព្រាហ្មណ៍ឬសាសនិកនិកាយព្រះនារាយណ៍។ |
| ភូម្យាករ | (សំ.) ដីនិងភោគផលនៅលើដីនោះ។ |
| មាសិ | ខ្នាតវាស់ប្រេង។ |
| មុខគាបិផ្តោលិ | ពាក្យនេះដូចនឹងពាក្យ ខ្មោញផ្តោលិ គឺមេខាងពួកឈ្មួល។ |
| រាជកុលមហាមន្ត្រី | មហាមន្ត្រីមានតួនាទីជាអ្នកប្រៀនប្រដៅសែរាជវង្ស។ |
| លេងសំគណ | ឡើងទៅរួមផ្សំជាក្រុមជាមួយទីដទៃ។ |
| សិទ្ធិ | (សំ.) សិទ្ធិជាអ្នកសម្រេច ជាអ្នកគ្រប់គ្រងកាន់កាប់...។ |

អត្ថបទដោយៈ ហ៊ុន ឈុនគេង និង ប៉ៅ សុខរីន

**សូត្រ្ត/សុតន្ត្រ** (សំ.) នៅក្រោមការគ្រប់គ្រងចាត់ចែង។

**អក្សូត** (សំ.) ស្រូវ។

**អមយ៌្យាទ** (សំ.) គ្មានមារយាទ គ្មានសណ្ដាប់ គ្មានដែនកំណត់។

**អវធិ** (សំ.) ទីកំណត់ ព្រំដែន។

## បញ្ជីឯកសារ


វង់ សុផាន់. (២០១៦). សិលាចារឹកនៃប្រទេសកម្ពុជាសម័យអង្គរ (ទំ. ២៩). ភ្នំពេញ.

Cœdès, George. (1964). Stèle de Nông P′ang P′uey. *Inscriptions du Cambodge* (Vol. VII, pp. 137-40). Paris: Editions de Boccard.

อำไพ คำโท, “คำอ่านศิลาจารึกอักษรขอมภาษาขอม ได้มาจากบ้านพังพวย อ. อรัญประเทศ จ. ปราจีนบุรี,” ศิลปากร 16, 1 (พฤษภาคม 2515) : 61-66.

อำไพ คำโท, “จารึกบ้านพังพวย,” ใน จารึกในประเทศไทย เล่ม 3 : อักษรขอม พุทธศตวรรษที่ 15-16 (กรุงเทพฯ : หอสมุดแห่งชาติ กรมศิลปากร, 2529), 50-56.


## គេហទំព័រ

SEALANG: http://sealang.net/ok/corpus.htm

SAC: https://db.sac.or.th/inscriptions/inscribe/detail/316

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ៅ សុខរីន

# បញ្ជីរូបភាព



សំណៅសិលាចារឹកភូមិកំពីងពួយ K.៩៥៧

(រូបថត៖ សាកលវិទ្យាល័យសិល្បាករ តាមរយៈ៖ https://db.sac.or.th/inscriptions/inscribe/detail/316)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ពៅ សុខរីន



សំណៅសិលាចារឹកភូមិកំពីងពួយ K.៩៥៧
(រូបថត៖ សាកលវិទ្យាល័យសិល្បករ តាមរយៈ៖ https://db.sac.or.th/inscriptions/inscribe/detail/316)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង និង ប៉ៅ សុខរីន